ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងព័ត៌មាន

MINISTRY OF INFORMATION

លេខ ៣៥៣/០៥ ព.ម

រាជធានីភ្នំពេញ, ថ្ងៃទី ០១ ខែ [illegible] ឆ្នាំ ២០០៥

# ប្រកាស

## ស្តីពីការបង្កើត ការិយាល័យពត៌មានវិទ្យា

## រដ្ឋមន្ត្រី ក្រសួងពត៌មាន

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស.រកត ០៧០៤-១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២.ន.ស.៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស-រកម-០១៩៦-១៤ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតក្រសួងព័ត៌មាន
- បានឃើញអនុក្រឹត្យលេខ២០ អនក្រ-បក ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ១៩៩៦ ស្តីពីការរៀបចំ និងប្រព្រឹត្តទៅ របស់ក្រសួង និងរដ្ឋលេខាធិការដ្ឋាន
- បានឃើញអនុក្រឹត្យលេខ៧០ អនក្រ.បក ចុះថ្ងៃទី០៥ ខែសីហា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ របស់ក្រសួងព័ត៌មាន
- យោងតាមតំរូវការចាំបាច់

## សំរេច

**ប្រការ ១.-**

ប្រកាសនេះ កំណត់ការបង្កើត និង រៀបចំភារកិច្ច របស់ការិយាល័យ ព័ត៌មានវិទ្យា ។

បង្កើតការិយាល័យព័ត៌មានវិទ្យា ចំណុះឱ្យអគ្គនាយកដ្ឋាន រដ្ឋបាល សោតទស្សន៍ និង ក្រោមការគ្រប់គ្រងដឹកនាំផ្ទាល់របស់ថ្នាក់ដឹកនាំអគ្គនាយកដ្ឋាន ។

**ប្រការ ២.-**

ការិយាល័យព័ត៌មានវិទ្យា មានភារកិច្ច ÷

- លើកផែនការទូទៅ រយៈពេលខ្លី-វែង លើវិស័យព័ត៌មានវិទ្យា
- គ្រប់គ្រង គេហទំព័រក្រសួង
- ត្រួតពិនិត្យ-ថែទាំ - ជួសជុល ផ្នែកទន់ និង ផ្នែករឹង នៃព័ត៌មានវិទ្យា
- គ្រប់គ្រងបណ្តាញប្រព័ន្ធតភ្ជាប់
- គ្រប់គ្រងទិន្នន័យកុំព្យូទ័រ
- ស្រាវជ្រាវ និងបំប៉នជំនាញ លើវិស័យព័ត៌មានវិទ្យា។

ការិយាល័យព័ត៌មានវិទ្យា ដឹកនាំដោយនាយការិយាល័យមួយរូប មានមុខតំណែងជាប្រធានការិយាល័យ (រដ្ឋបាលកណ្តាល) អមដោយនាយរងការិយាល័យមួយចំនួន ជាជំនួយការ និង មានមុខតំណែងជាអនុប្រធានការិយាល័យ (រដ្ឋបាលកណ្តាល) ។

**ប្រការ ៣.-**

ការិយាល័យព័ត៌មានវិទ្យាមានផ្នែកចំណុះ ដូចមានចែងខាងក្រោម ÷

**ក** - ផ្នែកទន់ មានភារកិច្ច ÷

- គ្រប់គ្រងកម្មវិធីមានអាជ្ញាប័ណ្ណទាំងអស់ដែលប្រើប្រាស់ក្នុងក្រសួង
- ត្រួតពិនិត្យ-ថែទាំ និង ជួសជុល កែលំអ លើគ្រប់កម្មវិធីដែលមាន និង កំពុងប្រើប្រាស់
- បង្កើតកម្មវិធីសំរាប់ប្រើប្រាស់ផ្ទាល់តាមតំរូវការចាំបាច់។

**ខ** - ផ្នែករឹង មានភារកិច្ច ÷

- គ្រប់គ្រងឧបករណ៍-សំភារៈ និងគ្រឿងបន្លាស់ព័ត៌មានវិទ្យា របស់ការិយាល័យព័ត៌មានវិទ្យា
- គ្រប់គ្រងទិន្នន័យកុំព្យូទ័រ
- គ្រប់គ្រងបណ្តាញប្រព័ន្ធតភ្ជាប់
- ត្រួតពិនិត្យ - ថែទាំ - ជួសជុល បណ្តាញ និង រាល់ឧបករណ៍សំភារៈទាំងឡាយដែលមាន និង កំពុងប្រើប្រាស់។

**គ** - ផ្នែករចនាប្លង់ និង រូបភាព មានភារកិច្ច ÷

- ចាត់ចែងធ្វើការតុបតែងលំអលើប្លង់សំរាប់ផ្សព្វផ្សាយទូទៅ
- ធ្វើឱ្យទាន់សម័យគេហទំព័រក្រសួងព័ត៌មាន។

**ឃ** - ផ្នែកបញ្ចូលទិន្នន័យ មានភារកិច្ច ÷

- វាយអត្ថបទ

- ស្កេនឯកសារ និង រូបភាពផ្សេងៗ
- ថតចំលង ស៊ីឌី និង ឌីវីឌី
- បញ្ចូល និង បញ្ជូន រាល់ទិន្នន័យទៅក្នុងគេហទំព័រក្រសួងព័ត៌មាន
- គ្រប់គ្រងសារអេឡិចត្រូនិច ។

ង - ផ្នែកស្រាវជ្រាវ និង បំប៉នជំនាញ មានភារកិច្ច ÷

- លើកផែនការទូទៅ រយៈពេលខ្លី-វែង លើវិស័យព័ត៌មានវិទ្យា
- សិក្សាបន្ថែម និងស្រាវជ្រាវវិស័យព័ត៌មានវិទ្យាឱ្យបានទាន់ការវិវឌ្ឍន៍
- បំប៉នជំនាញព័ត៌មានវិទ្យាបន្ថែមដល់មន្ត្រីរាជការក្រសួង និង មន្ទីរខេត្ត ក្រុង ។

**ប្រការ ៤.-**

រចនាសម្ព័ន្ធរបស់ការិយាល័យព័ត៌មានវិទ្យា ត្រូវដាក់បញ្ចូលបន្ថែមក្នុងឧបសម្ព័ន្ធនៃប្រកាស លេខ ៣០៣/០២ ពម.ប្រក ចុះថ្ងៃទី ២៧ ខែ វិច្ឆិកា ឆ្នាំ ២០០២ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅរបស់អគ្គនាយកដ្ឋាន រដ្ឋបាល សោតទស្សន៍ ។

**ប្រការ ៥.-**

រាល់ប្រកាសណាដែលផ្ទុយពីប្រកាសនេះត្រូវទុកជានិរាករណ៍ ។

**ប្រការ ៦.-**

អគ្គនាយកដ្ឋានរដ្ឋបាល សោតទស្សន៍ គ្រប់អគ្គនាយដ្ឋានចំណុះក្រសួងព័ត៌មាន និងអង្គភាពពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះ តាមភារកិច្ចរៀងៗខ្លួនឱ្យមានប្រសិទ្ធភាពខ្ពស់ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រដ្ឋមន្ត្រី

ខៀវ កាញារីទ្ធ

**<u>ចំលងជូន</u>**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ
- អគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាកំណែទំរង់រដ្ឋបាល
- ក្រសួងផែនការ

"ដើម្បីជូនជ្រាបជាព័ត៌មាន"

- រាជកិច្ច
- ឯកសារ